# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្ដីប្រកាសព័ត៌មាន</u>

ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២០

## ផ្ដល់កិត្តិយសជូន លោក ឃុយ មុយ

កាលពីសប្ដាហ៍មុន ក្រុមគ្រួសារស្ថានទូតអូស្ត្រាលី បានចូលរួមគ្នាដើម្បីផ្ដល់កិត្តិយសដល់សមាជិកម្នាក់ នៃសមាជិកដែលបម្រើសេវាកម្មយូរបំផុតរបស់គ្រួសារស្ថានទូត គឺ លោក ឃុយ មុយ។

លោក មុយ ដែលបានចាប់ផ្ដើមការងារដំបូងនៅស្ថានទូតក្នុងឆ្នាំ១៩៥៧ បានបម្រើដោយភាពក្លាហាន និងការលះបង់ អស់រយៈពេលជាង៣០ឆ្នាំ។

ល្បីល្បាញបំផុត គឺ លោក មុយ ត្រូវបានប្រគល់កូនសោស្ថានទូត នៅពេលដែលអ្នកការទូតអូស្ត្រាលី បានដកខ្លួនចេញពីប្រទេសកម្ពុជា នៅដើមឆ្នាំ១៩៧៥។ គាត់បន្តស្នាក់នៅស្ថានទូត រហូតដល់ត្រូវបង្ខំឱ្យចាកចេញ ដោយចុងកាំភ្លើង ដោយពួកខ្មែរក្រហម។ បន្ទាប់មកគាត់បានកប់កូនសោ និងប័ណ្ណស្ថានទូតរបស់គាត់ ដើម្បីរក្សាសុវត្ថិភាព។ បន្ទាប់ពីឆ្លងកាត់ការបាត់បង់ និងការលំបាកផ្ទាល់ខ្លួនយ៉ាងច្រើន នៅពេលដែលអ្នកការទូតអូស្ត្រាលីបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅដើមទសវត្សឆ្នាំ១៩៩០ លោក មុយ បានទទួលស្វាគមន៍ពួកគេ និងប្រគល់កូនសោជូនពួកគាត់វិញ។ គាត់ត្រូវបានគេផ្ដល់ការងារនៅនឹងកន្លែង ហើយបានធ្វើការជាអ្នកបើកបររបស់ឯកអគ្គរាជទូត រហូតដល់ឆ្នាំ២០០៣។

នៅយប់ថ្ងៃសុក្រ ក្នុងពិធីអបអរសាទរតូចមួយ ដើម្បីស្វាគមន៍បុគ្គលិក និងក្រុមគ្រួសារនៅកម្ពុជាដែលបានវិលត្រឡប់មកពីអូស្ត្រាលីវិញដោយសារកូវីដ-១៩ ក៏ដូចជាដើម្បីស្វាគមន៍បុគ្គលិកស្ថានទូតថ្មី ឯកអគ្គរាជទូត Kang មានមោទនភាពក្នុងការប្ដូរតំបន់សង្គមរបស់ស្ថានទូតថា "លោក ឃុយ មុយ បារ "។

លោកឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា៖ "លោក ឃុយ មុយ បារ គឺជាកន្លែងដែលត្រូវបានប្រើសម្រាប់ការជួបជុំសង្គម សម្រាប់ស្ថានទូត និងសហគមន៍អូស្ត្រាលីនៅកម្ពុជា។ វាជាកន្លែងដែលគ្រួសារយើងជួបជុំគ្នា។ វាគឺជាកិត្តិយសណាស់ ក្នុងការប្ដូរឈ្មោះន្លែងជាកិត្តិយសជូនដល់សមាជិកដ៏យូរបំផុតនៃគ្រួសាររបស់យើងគឺ លោក មុយ"។

បុគ្គលិកស្ថានទូតអូស្ត្រាលី និងខ្មែរជាច្រើននាក់មានសេចក្តីសោមនស្សរីករាយចំពោះ វត្តមានរបស់ លោក មុយ។ បុគ្គលិកបាននិយាយថា វាជាឯកសិទ្ធិដែលបានជួប លោក មុយ និងភរិយារបស់លោក គឺលោកស្រី ឈឹម អូន។ យើងយកភាពក្លាហាន ការលះបង់ និងការលះបង់ខ្លួនឯង ទាំងនេះជាគំរូ។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au




ឯកអគ្គរាជទូតKang និង លោក ឃុយ មុយ



លោក យុយ  មុយ (ទីពីររាប់ពីឆ្វេង) និងភរិយារបស់គាត់ លោកស្រី ឈឹម អួន (ទីបីរាប់ពីស្តាំ) ព្រមទាំងបុគ្គលិកស្ថានទូត



ឯកអគ្គរាជទូត Kang និង លោក យុយ  មុយ ព្រមទាំងបុគ្គលិកស្ថានទូត